# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ព្រះពុទ្ធសំដែងថា ខ្លួនជាអនត្តា តើមានទំនាស់ នឹងការថែរក្សាទឹកដីឬទេ ?

**Website: www.hoksavann.org**

ថ្ងៃទី១២ កុម្ភៈ ២០១០



ព្រះពុទ្ធសំដែងនៅក្នុងបរមត្ថអភិធម្មថា ខ្លួនមនុស្សសត្វដែលចែកជារូបរាងកាយនិងចិត្តវិញ្ញាណ ជាអនត្តាមិនមែនខ្លួនប្រាណ ក្នុងន័យថាជាសភាវធម៌កើតហើយរលត់ទៅវិញតាមធម្មតា មិនស្ថាប់បង្កាប់ ។ ប៉ុន្តែទោះបីសភាវៈពិតកើតឡើងដូច្នេះក៏ដោយ ក៏ព្រះពុទ្ធបានថែរក្សាខ្លួនប្រាណដូចក្នុងទុក្ខសច្ចៈ ក្នុងអរិយសច្ចៈ៤ ព្រះពុទ្ធសំដែងដោយតាំងជាសំនួរថា អ្វីជាទុក្ខ ? ចម្លើយថា ខន្ធ៥ជាទុក្ខ ។ បើខន្ធ៥ជាទុក្ខ តើត្រូវមានកិច្ចធ្វើដូចម្តេច ? ត្រូវកំណត់ដឹង គឺកំណត់ថាខន្ធ៥ជាទុក្ខ ។ ពិតមែនតែខ្លួនប្រាណមនុស្សសត្វដែលចាត់ជាខន្ធ៥មានរូបក្ខជាដើមជាតួទុក្ខ គឺព្រះពុទ្ធឲ្យថែរក្សាខន្ធ៥នេះឲ្យរស់នៅបានសុខស្រួលទាំងបព្វជិតទាំងគ្រហស្ថ ដោយស្វែងរកបច្ច័យ៤មានចីវរបច្ច័យជាដើម ដើម្បីឲ្យជីវិតរស់នៅបាន ។

តាមការរៀបរាប់ខាងលើនេះបញ្ជាក់ថា ពិតមែនខ្លួនជាអនត្តាតាមច្បាប់ធម្មជាតិ ប៉ុន្តែខ្លួនជាកម្មសិទ្ធិរបស់ខ្លួន ត្រូវរក្សាការពារជីវិត ជៀសវាងការបៀតបៀនពីអ្នកដទៃ ។ ក្រៅពីជីវិតខ្លួន ត្រូវរក្សាការពារកម្មសិទ្ធិដទៃទៀត មិនត្រឹមតែទឹកដីទេ គឺរក្សាឯករាជ្យ អធិបតេយ្យជាតិឲ្យបានគង់វង់ស្ថិតស្ថេរ ។ ពាក្យយ៉ាងសាមញ្ញថា ចុះបើបរទេសរំលោភយកទឹកដីអស់ទៅ តើពុទ្ធសាសនិកជនខ្មែរត្រូវការសង់វត្តទៅសង់កន្លែងណា ? ដូច្នេះត្រូវរក្សាការពារទឹកដីខ្មែរឲ្យបានគង់វង់ កុំឲ្យបរទេសជិតខាងទាំងពីររំលោភយកតទៅទៀត ។ បើអស់ឯករាជ្យ អស់អធិបតេយ្យជាតិវិញ ក៏យើងមិនអាចធ្វើអ្វីតាមបំណងរបស់យើងឡើយ ។ ច្បាស់ជាងនេះទៅទៀត ធម៌ប្រយោជន៍បច្ចុប្បន្ន៤យ៉ាងមានឧបដ្ឋានសម្បទា គឺយុវវ័យត្រូវខំប្រឹងប្រែងសិក្សារៀនសូត្រ និងអប់រំចរិយាឲ្យបានល្អ ។ មធ្យមវ័យត្រូវខំរកស៊ីចិញ្ចឹមជីវិតប្រកបដោយធម៌ បើអ្នករដ្ឋការត្រូវបំពេញការងារឲ្យបានល្អតាមមុខងាររបស់ខ្លួន ។ អារក្ខសម្បទា ចំណេះវិជ្ជានិងរបស់ដែលរកបានហើយនិងទ្រព្យសម្បត្តិរបស់ជាតិ ត្រូវរក្សាឲ្យបានគង់វង់ជាដើម ។ តាមន័យនេះ ព្រះពុទ្ធបានបង្រៀនឲ្យមនុស្សបំពេញការងារដែលឥតទោស ដោយមិនខ្ជិលច្រអូសនិងថែរក្សាសម្បត្តិរបស់ខ្លួននិងសម្បត្តិរបស់ជាតិកុំឲ្យបាត់បង់ ។ បានសេចក្តីថា ត្រូវមានជីវភាពរស់នៅក្នុងបច្ចុប្បន្នឲ្យបានល្អប្រសើរ ទើបការប្រតិបត្តិដើម្បីនិព្វានមានប្រសិទ្ធិភាព ។

ពុទ្ធភាសិតមួយបទពោលថា អរោគ្យា បរមាលាភា ប្រែថាការមិនមានរោគជាលាភដ៏ប្រសើរ ។ត្រង់ពុទ្ធភាសិតនេះបញ្ជាក់ថា ព្រះអង្គឲ្យតម្លៃថា ការថែរក្សាខ្លួនប្រាណឲ្យមានសុខភាពល្អ ជាការប្រពៃណាស់ ព្រោះអ្វី ? ព្រោះថាការមានសុខភាពល្អមានអាយុវែង អាចមានពេលវេលាប្រតិបត្តិធម៌ ឆ្ពោះទៅរកការរំដោះទុក្ខឲ្យបានយូរអង្វែង ។ បានសេចក្តីថា យកខ្លួនដែលជាអនត្តានេះ សំរាប់ប្រើការដើម្បីរំដោះទុក្ខ ។ ប៉ុន្តែបើរស់នៅយូរធ្វើបាបទៅវិញ នោះពុំមែនជាគោលបំណងនៃពុទ្ធភាសិតនេះឡើយ ព្រោះអ្វី ? ព្រោះថា ការរស់នៅយូរដរាបណា ដរាបនោះការសន្សំអំពើបាបកាន់តែច្រើនឡើងដែរ ។

ពុទ្ធភាសិតខាងលើនេះ ជាចម្លើយតបទៅនឹងពាក្យថា បើរូបរាងកាយរបស់មនុស្សសត្វដែលព្រះពុទ្ធសំដែងថាជាអនត្តាពុំមែនជារូបរាងកាយរបស់ខ្លួនទេ តើចាំបាច់អ្វីដែលត្រូវថែទាំរូបរាងកាយនេះ ។ តាមសេចក្តីនៅក្នុងបរមត្ថអភិធម្មសំដែងថា ខ្លួនប្រាណចិត្តវិញ្ញាណតែងប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា គឺជាសភាវធម៌កើតឡើង ហើយតែងតែរលត់ទៅវិញជាធម្មតា ។ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងមនោ ដែលជាអាយតនៈខាងក្នុង និងរូប សម្លេង ក្លិន រស សម្ផស្ស និងធម្មា (អារម្មណ៍ដែលចិត្តគោង) ជាអាយតនៈខាងក្រៅ សុទ្ធសឹងតែជាសភាវធម៌ កើតឡើងហើយតែងតែរលត់ទៅវិញ មិនស្ថាប់បង្កាប់ ។ ចំណែកចិត្តវិញ្ញាណដែលជានាមធម៌ ដែលកើតពីអាយនៈខាងក្នុងនិងខាងក្រៅប៉ះ (ផស្សៈ) គ្នា កើតជាចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ ក៏ជាសភាវធម៌កើតឡើងហើយ តែងតែរលត់ទៅវិញដូចគ្នា ។ បានសេចក្តីថា រូបធម៌និងនាមធម៌នេះ តែងកើតឡើងពីហេតុបច្ច័យ វាតែងតែរលត់ទៅវិញ ដោយគ្មានអ្វីជាម្ចាស់ឡើយ ។ នេះជាសភាវៈពិតតាមបរមត្ថធម៌ ដែលជាធម៌ដ៏ល្អិត ដែលដឹងបានតាមផ្លូវវិបស្សនា ដែលជាលោកុត្តរបញ្ញាដ៏ជ្រៅរបស់ព្រះអរិយបុគ្គលទាំងឡាយ ចាប់ពីលោកអ្នកបានសំរេចសោតាឡើងទៅ ។ បរមត្ថធម៌នេះ គេពុំបានដឹងច្បាស់លាស់តាមការត្រិះរិះធម្មតាឡើយ ។ ទ្រឹស្តីអនត្តានេះ តាមសាសនាព្រាហ្មណ៍យល់ថា រូបកាយរបស់មនុស្សសត្វកាលណាស្លាប់ទៅ រូបកាយនេះត្រូវរលាយទៅជាដីទឹកភ្លើងខ្យល់ដូចពុទ្ធសាសនាបានពោល ប៉ុន្តែចិត្តវិញ្ញាណមិនរលាយឡើយ តែងតែអណ្តែតត្រសែតទៅរកទីកើត ទស្សនៈនេះព្រះពុទ្ធបានបដិសេធ ។ ព្រះពុទ្ធបានពន្យល់ថា រូបកាយនិងចិត្តវិញ្ញាណរបស់មនុស្សសត្វ កាលណាដាច់ខ្យល់ស្លាប់ ត្រូវស្លាប់ទាំងរូបកាយ តាំងចិត្តវិញ្ញាណ គ្មានអ្វីសល់នៅឡើយ ប៉ុន្តែអ្វីដែលកើតទៀតនោះ គឺជាវិបាករបស់កម្មដែលមនុស្សសត្វបានកសាង (កម្មយោនិ) ។

តាមការរៀបរាប់មកហើយ ជាចម្លើយតបទៅនឹងប្រធានបទ គឺព្រះពុទ្ធសំដែងថា ខ្លួនជាអនត្តាពុំទំនាស់នឹងការថែរក្សា

ទឹកដីទេ ។ ផ្ទុយទៅវិញ ព្រះពុទ្ធបានដាស់តឿនឲ្យមនុស្សគ្រប់រូបខំថែទាំរបស់ដែលមាន ស្វែងរករបស់ដែលបាត់បង់ ជួសជុលរបស់ដែលខូចខាត នៅក្នុងធម៌ដែលជាប្រយោជន៍បច្ចុប្បន្នវិញទេ ។ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនា ក៏ព្រះពុទ្ធបានអនុញ្ញាតឲ្យព្រះសង្ឃស្វែងរកបច្ច័យ៤ គឺចីវបច្ច័យ បិណ្ឌបាតបច្ច័យ សេនាសនបច្ច័យ និងគិលានភេសជ្ជបច្ច័យ ដើម្បីការរស់នៅរបស់ព្រះសង្ឃដែលហៅថាករណីយកិច្ច គឺកិច្ចដែលព្រះសង្ឃត្រូវធ្វើដែរ ។

ដូច្នេះទ្រឹស្ដីអនត្តា ពុំមែនឲ្យលះបង់ខ្លួនប្រាណ មិនគិតពីសុខភាព មិនគិតពីការរស់នៅ មិនឲ្យរក្សាការពាររបស់ដែលមាន មានទឹកដីជាដើមឡើយ ។៚

❊ ❊

❊